# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ០៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូបឹងកេត

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពី ការអនុវត្តន៍ព្រះរាជក្រម ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល
- បានឃើញកិច្ចសន្យាទិញ-លក់ និង កិច្ចសន្យាជួលដី ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ រវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុនឡុងស្រេងអន្តរជាតិ ( Long Sreng International Co., Ltd.)

-តាមសំណើរបស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍ប្រយោគរបស់រដ្ឋ លើសមាគ្រោងចំការកៅស៊ូ ក្រុមហ៊ុនសំការៈកសិកម្ម និង ក្រុមហ៊ុនផលិតផល

## ស ម្រេ ច

មាត្រា ១ : បញ្ចប់ស្ថានភាពគតិយុត្តិចំការកៅស៊ូបឹងកេតដែលជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ចាប់ពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ តទៅ។

មាត្រា ២ : ផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូបឹងកេត ទៅឱ្យក្រុមហ៊ុនឡុងស្រេងអន្តរជាតិ ( Long Sreng International Co., Ltd.) ដើម្បីបន្តគ្រប់គ្រងស្របតាមបទប្បញ្ញត្តិនានាដែលបានកំណត់ក្នុងកិច្ចសន្យាទិញ-លក់ និង កិច្ចសន្យាជួលដី ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ រវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុនឡុងស្រេងអន្តរជាតិ ( Long Sreng International Co., Ltd.) ចាប់ពីថ្ងៃ ទី ១០ ខែ មករា ឆ្នាំ ២០០៨ តទៅ។

មាត្រា ៣ : រំសាយក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូបឹងកេត ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យលេខ ៨៩១ អនក្រ-តត ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៩ ត្រង់ ចំណុច ៤ នៃមាត្រា១ រំសាយប្រធានអគ្គនាយកចំការកៅស៊ូបឹងកេត និង រំសាយមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូបឹងកេត ដែលត្រូវតែងតាំងដោយអនុក្រឹត្យលេខ ៨២៥ អនក្រ តត ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ចាប់ពីថ្ងៃ ទី ១០ ខែ មករា ឆ្នាំ ២០០៨ តទៅ។

មាត្រា ៤ : ផ្ទេរឯកឧត្តម ស៊ឹម វណ្ណា ប្រធានអគ្គនាយកចំការកៅស៊ូបឹងកេត ចូលមកបំរើការងារក្នុងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទវិញ ចាប់ពីថ្ងៃ ទី ១០ ខែ មករា ឆ្នាំ ២០០៨ តទៅ។

មាត្រា ៥: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកដោះស្រាយបន្ត រាល់បំណុលត្រូវទារ និង ត្រូវសងទាំងអស់ រវាងចំការកៅស៊ូបឹងកេត និង បណ្តាក្រុមហ៊ុន ស្ថាប័ននានានិងអតិថិជន និង បន្តស្រាវជ្រាវនិងប្រមូលចំណូលបានពីការកាប់ដើមកៅស៊ូចាស់ៗដែលមិនត្រូវបានយកទៅប្រើប្រាស់សំរាប់ការដាំដុះឡើងវិញ ដើម្បីបង់ចូលថវិការដ្ឋ។

មាត្រា ៦: ចំការកៅស៊ូបឹងកេត ត្រូវប្រគល់ត្រា និងឯកសារពាក់ព័ន្ធទាំងអស់ រួមទាំងឯកសារក្នុងកុំព្យូទ័រ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីរក្សាទុក។

មាត្រា ៧ : ថវិកាដែលនៅសល់ក្នុងគណនី និង របឡា របស់ចំការកៅស៊ូបឹងកេត ត្រូវផ្ទេរចូលថវិការដ្ឋ។ បិទរាល់គណនីធនាគារទាំងអស់របស់ចំការកៅស៊ូបឹងកេត ចាប់ពីថ្ងៃ ទី ១០ ខែ មករា ឆ្នាំ ២០០៨ តទៅ។

មាត្រា ៨ : អនុក្រឹត្យលេខ ១៧ អនក្រ-បក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពី ការបង្កើតចំការកៅស៊ូបឹងកេត ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ចាប់ពីថ្ងៃ ទី ១០ ខែ មករា ឆ្នាំ ២០០៨ តទៅ។

មាត្រា ៩ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម-រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី